**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
**គណៈកម្មការរៀបចំការប្រឡងប្រជែង**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការទទួលស្គាល់សាធារណជន ជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត ដែលត្រូវចូលរួម ក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារ នៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (វិញ្ញាសាសរសេរលើកទី១)

យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មការរៀបចំការប្រឡងប្រជែងចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ ស្តីពី ការទទួលសាធារណជនចុះឈ្មោះជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត ឱ្យចូលរួមក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារនៅ**អគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (វិញ្ញាសាសរសេរលើកទី១)** គណៈកម្មការរៀបចំការប្រឡងប្រជែង សូមប្រកាសទទួលស្គាល់ **"អ្នកសង្កេតការណ៍ជាសាធារណជន"** ចំនួន**២០នាក់** ដែលត្រូវបានបែងចែកតាមកាលបរិច្ឆេទនិងមណ្ឌល ដូចមានរាយនាមខាងក្រោម៖

**ក. ថ្ងៃសៅរ៍ ទី២៨ ខែធ្នូ ឆ្នាំ២០២៤ (មណ្ឌលប្រឡង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)**

| ល.រ | គោត្តនាម និងនាម | ភេទ | មុខរបរ | មកពី |
|---|---|---|---|---|
| ១ | ស៊ុំ សុនីតា | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ២ | ជុំ ចាន់រាត្រី | ប្រុស | និស្សិត | រាជធានីភ្នំពេញ |
| ៣ | អ៊ុម ស្រីនាថ | ស្រី | និស្សិត | ខេត្តកណ្តាល |
| ៤ | សាន បញ្ញា | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ៥ | សៀវ អាយគីង | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ៦ | ទេព ភារិទ្ធ | ប្រុស | មន្ត្រីរាជការ | រាជធានីភ្នំពេញ |
| ៧ | កែវ ពេជ្រលីឌីនេត្រ | ស្រី | មន្ត្រីរាជការ | រាជធានីភ្នំពេញ |
| ៨ | ជិត ចាន់ធូ | ប្រុស | គ្រូបង្រៀន | រាជធានីភ្នំពេញ |
| ៩ | សួប ម៉ើរីយ៉ាស់ | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ១០ | ស្រ៊ុន ចន្ទី | ប្រុស | មន្ត្រីកិច្ចសន្យា | រាជធានីភ្នំពេញ |

## ខ. ថ្ងៃអាទិត្យ ទី២៩ ខែធ្នូ ឆ្នាំ២០២៤ និងថ្ងៃបន្តបន្ទាប់ (មណ្ឌលកំណែៈ សាលាភូមិន្ទរដ្ឋបាល)

| ល.រ | គោត្តនាម និងនាម | ភេទ | មុខរបរ | មកពី |
|---|---|---|---|---|
| ១ | ខុន ចំរើន | ប្រុស | ព្រះសង្ឃ | ខេត្តកំពង់ស្ពឺ |
| ២ | ផល ផានិត | ប្រុស | បុគ្គលិកក្រុមហ៊ុនឯកជន | រាជធានីភ្នំពេញ |
| ៣ | ឃុន ផាន់ណាង | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ៤ | គីម រុន | ប្រុស | បុគ្គលិកក្រុមហ៊ុនឯកជន | រាជធានីភ្នំពេញ |
| ៥ | ឈិនផន ពៅពិសី | ប្រុស | និស្សិត | ខេត្តស្វាយរៀង |
| ៦ | ឡាប ផាលីន | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ៧ | និន ឡា | ប្រុស | និស្សិត | រាជធានីភ្នំពេញ |
| ៨ | ឃុន ផាន់ណាង | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ៩ | ញ៉ុញ សុខុមាម្រឹតវតី | ស្រី | និស្សិត | រាជធានីភ្នំពេញ |
| ១០ | បូ យ៉ាន់អ៊ី | ស្រី | និស្សិត | រាជធានីភ្នំពេញ |

**បញ្ជាក់៖ អ្នកសង្កេតការណ៍ស្ម័គ្រចិត្ត**ទាំងអស់ត្រូវមកដល់មណ្ឌលប្រឡងនៅម៉ោង (**៦:០០ព្រឹក**) និងមណ្ឌលកំណែ សាលាភូមិន្ទរដ្ឋបាល ឱ្យបានមុនម៉ោង (**៧:០០ព្រឹក**) តាមកាលបរិច្ឆេទនិងមណ្ឌលដូចបានបញ្ជាក់ខាងលើ ដើម្បីទទួលយកប័ណ្ណសម្គាល់ខ្លួន និងព័ត៌មានពាក់ព័ន្ធផ្សេងៗ៕ ***(សូមអានបទប្បញ្ញត្តិសម្រាប់អ្នកសង្កេតការណ៍ដូចមានជូនភ្ជាប់)***

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០២៤

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
គណៈកម្មការរៀបចំការប្រឡងប្រជែង

# បទប្បញ្ញត្តិ
## សម្រាប់អ្នកសង្កេតការណ៍ក្នុងដំណើរការប្រឡងប្រជែងជ្រើសរើស
## មន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារតាមក្រសួង-ស្ថាប័ន

ដើម្បីឱ្យការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារតាមក្រសួង-ស្ថាប័ន ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យប្រកបដោយគុណាធិបតេយ្យ **តម្លាភាព យុត្តិធម៌ បរិយាបន្ន** និងប្រសិទ្ធភាព គណៈកម្មការរៀបចំការប្រឡងប្រជែងសូមដាក់ចេញនូវបទប្បញ្ញត្តិសម្រាប់អ្នកចូលរួមសង្កេតការណ៍ដូចខាងក្រោមៈ

### ១) សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍

- មានសិទ្ធិចូលទៅសង្កេតការណ៍ដល់អគារប្រឡង និងនៅខាងក្រៅបន្ទប់ប្រឡង
- ត្រូវប្រើឯកសណ្ឋានសម្គាល់ស្ថាប័នបំពេញការងារ ឬសំលៀកបំពាក់សមរម្យ និងពាក់កាតសម្គាល់ខ្លួនត្រឹមត្រូវ
- ត្រូវប្រតិបត្តិតាមការណែនាំរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង
- ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ ស្របតាមច្បាប់ លិខិតបទដ្ឋាន និងបទប្បញ្ញត្តិដទៃទៀត
- ធានាថា សកម្មភាពសង្កេតការណ៍របស់ខ្លួន មិនបង្កការរំខានដល់មន្ត្រីរៀបចំការប្រឡងប្រជែង និងបេក្ខជន
- ក្នុងករណីសង្កេតឃើញ ឬយល់ឃើញថា មានសកម្មភាពណាមួយមិនប្រក្រតី ត្រូវរាយការណ៍មកអនុគណៈកម្មការដែលគ្រប់គ្រងអ្នកសង្កេតការណ៍ភ្លាម ដើម្បីមានចំណាត់ការសមស្រប
- អាចផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការនៃការប្រឡងប្រជែងដល់គណៈកម្មការរៀបចំការប្រឡងប្រជែង។

### ២) បម្រាមចំពោះអ្នកសង្កេតការណ៍

- ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង
- ជជែកពិភាក្សា ឬផ្តល់សំណៅឯកសារផ្សេងៗដល់បេក្ខជននៅក្នុងបរិវេណមណ្ឌលប្រឡង
- យកទូរស័ព្ទ ឬគ្រឿងអេឡិចត្រូនិក ថតរូប ថតវីដេអូ ឬថតសំឡេងនៅក្នុងបរិវេណមណ្ឌលប្រឡងឡើយ
- សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត
- យកតាមខ្លួននូវអាវុធ ឬជាតិផ្ទុះ ឬវត្ថុដែលអាចបង្កគ្រោះថ្នាក់ចូលមណ្ឌលប្រឡង
- រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃការប្រឡងប្រជែង។

◀ ក្នុងករណីអ្នកសង្កេតការណ៍មិនអនុវត្តតាមបទប្បញ្ញត្តិ ឬការណែនាំរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង អ្នកសង្កេតការណ៍នោះនឹងត្រូវបណ្តេញចេញពីមណ្ឌលប្រឡង និង/ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។